**ព័ត៌មានអំពីលទ្ធផល នៃកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានក្រៅផ្លូវការលើកទី១៦**
**នៅទីក្រុងពូត្រាចាយ៉ា ប្រទេសម៉ាឡេស៊ី**

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ាន បានដឹកនាំគណៈប្រតិភូកម្ពុជាមួយក្រុម ទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ក្រៅផ្លូវការលើកទី ១៦ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២៧-២៨ ខែ កុម្ភៈ ឆ្នាំ ២០១០ នៅទីក្រុង ពូត្រាចាយ៉ា ប្រទេសម៉ាឡេស៊ី ។

លទ្ធផលសំខាន់ៗ នៃកិច្ចប្រជុំសម្រេចបានមានដូចជាការឯកភាពឱ្យវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ីបូព៌ា និងអាស៊ាន (ERIA) ធ្វើការសិក្សាពីការវិស័យនានាសម្រាប់ធ្វើឱ្យប្រសើរ ឡើងនូវតារាងពិន្ទុសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលរួមមានៈ សេរីភាវូបនីយកម្ម និងការសម្រួលវិនិយោគ, ការសម្រួលពាណិជ្ជកម្មផ្តោតលើប្រសិទ្ធភាពការងារគយ រួមទាំងធ្វើច្រកចេញ-ចូលតែមួយ របស់អាស៊ាន និងច្រកចេញ-ចូលតែមួយតាមប្រទេសនីមួយៗ, ការដឹកជញ្ជូនតាមផ្លូវអាកាស គោក និងសមុទ្រ និងសេវាភស្តុភារ ។ បានឯកភាព ឱ្យអាស៊ានផ្តោតការយកចិត្តទុកដាក់លើការបំបាត់របាំងមិនមែនពន្ធគយ និងការជំរុញសកម្ម ភាពសម្រួលពាណិជ្ជកម្ម ឱ្យកាន់តែស៊ីជំរៅថែមទៀត ។ ឯកភាពផ្តល់អាទិភាពលើការអនុវត្តគំរោង ផ្នែកកម្មសិទ្ធិបញ្ញា គោលនយោបាយប្រកួតប្រជែង និងការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់ហិរញ្ញប្បទាន ដែលអាចជួយបង្កើនប្រសិទ្ធិភាព ដល់ការកសាងសហគមន៍ សេដ្ឋកិច្ចអាស៊ាន និងធានា ដល់តុល្យភាពនៃការលូតលាស់ក្នុងតំបន់។ រកដំណោះស្រាយទាក់ទងនឹងការនាំចេញស្រូវ និងស្ករ រវាងប្រទេស ហ្វីលីពីន និងថៃ និងជំរុញឱ្យមានការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ។ ឯកភាពឱ្យប្រទេស វៀតណាមរៀបចំនីតិវិធីកាត់ បន្ថយពន្ធគយសម្រាប់ផលិតផលប្រេងឥន្ធនៈរបស់ខ្លួនឱ្យបាន ប្រហាក់ប្រហែល នឹងនីតិវិធីកាត់បន្ថយ ពន្ធគយសម្រាប់ផលិតផលប្រេង ឥន្ធនៈរបស់កម្ពុជា តែប្រើរយៈពេលខ្លីជាងកម្ពុជា។ បានទទួលការអញ្ជើញរបស់តំណាងពាណិជ្ជកម្ម អាមេរិកឱ្យទៅចូលរួមផ្សព្វផ្សាយ អំពីវឌ្ឍនភាពរបស់អាស៊ាន នៅសហរដ្ឋអាមេរិកពីថ្ងៃទី ៣-៥ ខែឧសភា ឆ្នាំ២០១០ នៅទីក្រុង ស៊ីអាតុល និងវ៉ាស៊ីនតោន ឌីស៊ី ដើម្បីជួបប្រជុំជាមួយ វិស័យឯកជន និងមន្ត្រីសំខាន់ៗ របស់រដ្ឋការលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា។ ស្នើឱ្យប្រទេសឥណ្ឌូណេស៊ី និងប្រទេសហ្វីលីពីន រៀបចំឱ្យបានចប់នូវបញ្ជីបំរុងទុករបស់ខ្លួនឱ្យបានរួចរាល់សម្រាប់កិច្ច ប្រជុំរដ្ឋមន្ត្រី សេដ្ឋកិច្ចអាស៊ានពិភាក្សានៅខែសីហា ខាងមុខនេះ។ កិច្ចប្រជុំក៏បានអនុមត័លើសេចក្តីព្រាងនៃសេចក្តីថ្លែងការណ៍ របស់ប្រមុខដឹកនាំអាស៊ាន ស្តីពីការងើបឡើងវិញនៃសេដ្ឋកិច្ចអាស៊ាន ដែលនឹងប្រកាសដោយប្រមុខរដ្ឋាភិបាលអាស៊ាន នៅក្នុង ខែមេសា ឆ្នាំ ២០១០ នៅទីក្រុងហាណូយ ខាងមុខនេះ ។ បានជំរុញឱ្យដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការបង្កើតតំបន់ពាណិជ្ជកម្ម សេរីរវាងអាស៊ាន និងប្រទេសដៃគូ ពិគ្រោះយោបល់ឱ្យបានឆាប់ ហើយកិច្ចប្រជុំនេះមានលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីធ្វើការពិនិត្យ វាយតំលៃឡើងវិញនូវការប្តេជ្ញាចិត្តនានារបស់ប្រទេសជាសមាជិក ក្នុងការអនុវត្តកាតព្វកិច្ចអាស៊ាន ដោយផ្អែកតាមតារាងពិន្ទុ សំរាប់ដំណើរការកសាងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយបានធ្វើការពិនិត្យតាមដាននូវការងារសំខាន់ៗមួយចំនួនដូចជាៈ កិច្ចព្រមព្រៀងពាណិជ្ជកម្ម ផ្នែកទំនិញ អាស៊ាន, កិច្ចព្រមព្រៀងវិនិយោគ ទូលំទូលាយអាស៊ាន, ពិធីសារអនុវត្តកញ្ចប់សន្យាផ្តល់ទី៧ ជាដើម ។